ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា

# គោលនយោបាយ ស្តីពី ការអប់រំបរិយាបន្ន

មិថុនា ២០១៨

ក្រសួងអប់រំ យុវជន និងកីឡា

# គោលនយោបាយ
# ស្តីពី
# ការអប់រំបរិយាបន្ន

មិថុនា ២០១៨

រក្សាសិទ្ធិគ្រប់យ៉ាង ឆ្នាំ២០១៨ ដោយនាយកដ្ឋានគោលនយោបាយ និងនាយកដ្ឋានអប់រំពិសេស/ក្រសួងអប់រំ យុវជន និងកីឡា

រក្សាសិទ្ធិគ្រប់បែបយ៉ាង មិនមានផ្នែកណាមួយនៃឯកសារនេះត្រូវបានយកទៅសរសេរឡើងវិញ ឬប្រើប្រាស់ក្នុងទម្រង់ ឬមធ្យោបាយបែបណាក៏ដោយ ដែលរួមមានការថតចម្លង ការកត់ត្រា ឬការថតទុកនៅក្នុងប្រព័ន្ធផ្ទុកព័ត៌មានផ្សេងៗទៀត ដោយគ្មានការអនុញ្ញាតជាលាយលក្ខណ៍អក្សរពីក្រសួងអប់រំ យុវជន និងកីឡាបានឡើយ។

នាយកដ្ឋានគោលនយោបាយ និងនាយកដ្ឋានអប់រំពិសេស
ក្រសួងអប់រំ យុវជន និងកីឡា
ភ្នំពេញ, ព្រះរាជាណាចក្រកម្ពុជា
ទូរសព្ទ៖ (៨៥៥) ២៣ ២១០ ៧៧៦
គេហទំព័រ៖ www.moeys.gov.kh

គំនិតរចនា និងសិល្បៈ ឆ្នាំ២០១៨ ដោយ បណ្ឌិត ឌី ខាំបូលី
រចនាក្រាហ្វិក ឆ្នាំ២០១៨ ដោយ លោក សុខ គង់

កម្ពុជា៖ គោលនយោបាយស្តីពីការអប់រំបរិយាបន្ន
ដោយ នាយកដ្ឋានគោលនយោបាយ និងនាយកដ្ឋានអប់រំពិសេស
បោះពុម្ពផ្សាយនៅកម្ពុជា ឆ្នាំ២០១៨

ជំនួយទ្រទ្រង់ផ្នែកហិរញ្ញវត្ថុសម្រាប់ការរៀបចំឯកសារគោលនយោបាយនេះ ត្រូវបានផ្តល់ដោយថវិកាកម្មវិធី ក្រសួងអប់រំ យុវជន និងកីឡា ឆ្នាំ២០១៧ និងមូលនិធិភាពជាដៃគូ សម្រាប់ការអភិវឌ្ឍសមត្ថភាព (CDPF)។

## **បុព្វកថា**

ប្រព័ន្ធអប់រំកម្ពុជាត្រូវបានបំផ្លាញទាំងស្រុងនៅចុងទសវត្សរ៍ឆ្នាំ១៩៧០។ ក្រោយមក តាមរយៈកិច្ចខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ក្រោមជំនួយឧបត្ថម្ភពីដៃគូអភិវឌ្ឍន៍ និងសហគមន៍អន្តរជាតិនានា វិស័យអប់រំនៅកម្ពុជាមានការរីកចម្រើនជាបន្តបន្ទាប់។ សាលាបឋមសិក្សាជាច្រើនត្រូវបានសាងសង់ឡើង ដើម្បីបំពេញតម្រូវការអប់រំរបស់កុមារនៅតាមមូលដ្ឋាន។ ជាមួយគ្នានេះដែរ អនុវិទ្យាល័យត្រូវបានបង្កើតដល់មូលដ្ឋានឃុំ សង្កាត់។ ក្រសួងអប់រំ យុវជន និងកីឡា បានអភិវឌ្ឍ និងអនុវត្តផែនការយុទ្ធសាស្ត្រវិស័យអប់រំ ដែលធានាការអប់រំមានគុណភាពប្រកបដោយសមធម៌ និងបរិយាបន្ន និងលើកកម្ពស់ឱកាសសិក្សាពេញមួយជីវិតសម្រាប់ទាំងអស់គ្នា។

ការិយាល័យអប់រំពិសេស ត្រូវបានបង្កើតឡើងនៅឆ្នាំ២០០០ ក្រោមនាយកដ្ឋានបឋមសិក្សា ដែលមានភារកិច្ចអភិវឌ្ឍការអប់រំកុមារពិការ កុមារជនជាតិដើមភាគតិច កុមារក្រីក្រ កុមារី និងកុមារជួបការលំបាក។ ការិយាល័យអប់រំពិសេស ត្រូវបានប្រែក្លាយទៅជានាយកដ្ឋានអប់រំពិសេសនៅឆ្នាំ២០១៦ ដែលមានវិសាលភាពគ្របដណ្តប់ការងារអប់រំបរិយាបន្នសម្រាប់ជនស្ថិតក្នុងសេចក្តីត្រូវការពិសេស ចាប់ពីកម្រិតមត្តេយ្យសិក្សារហូតដល់ឧត្តមសិក្សា។

ក្រសួងអប់រំ យុវជន និងកីឡា បានអភិវឌ្ឍគោលនយោបាយស្តីពីការអប់រំកុមារពិការនៅឆ្នាំ២០០៨ និងកែសម្រួលគោលនយោបាយនេះទៅជា**គោលនយោបាយស្តីពីការអប់រំបរិយាបន្ន**នៅឆ្នាំ២០១៨។ គោលនយោបាយស្តីពីការអប់រំបរិយាបន្ននេះ មានគោលបំណងបណ្តុះការអប់រំដល់ជនស្ថិតក្នុងសេចក្តីត្រូវការពិសេសឱ្យមានវិជ្ជាសម្បទា បំណិនសម្បទា និងចរិយាសម្បទាពេញលេញ ដើម្បីក្លាយខ្លួនជាសមាជិកសកម្ម និងអាចរស់នៅក្នុងសង្គមប្រកបដោយភាពសុខដុមរមនា។ គោលនយោបាយនេះមានវិសាលភាពលើការអប់រំចាប់ពីកម្រិតមត្តេយ្យសិក្សារហូតដល់ឧត្តមសិក្សា តាមគ្រឹះស្ថានសិក្សាសាធារណៈ និងឯកជន។ គោលនយោបាយស្តីពីការអប់រំបរិយាបន្ន ឆ្លើយតបទៅនឹងនិន្នាការអប់រំក្នុងតំបន់ និងសកលលោក ដោយរក្សានូវបរិបទអប់រំ និងវប្បធម៌របស់កម្ពុជា។

ក្រសួងអប់រំ យុវជន និងកីឡា សូមថ្លែងអំណរគុណដល់ក្រសួង ស្ថាប័ន និងដៃគូអភិវឌ្ឍន៍នានា ដែលបានគាំទ្រ និងបន្តចូលរួមផ្តល់សេវា និងលើកកម្ពស់គុណភាពអប់រំឱ្យកាន់តែល្អប្រសើរ ជាពិសេសសេវាអប់រំបរិយាបន្នសម្រាប់ជនស្ថិតក្នុងសេចក្តីត្រូវការពិសេស។

ថ្ងៃចន្ទ ១៣កើត ខែបឋមាសាឍ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២

រាជធានីភ្នំពេញ ថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០១៨

**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

**បណ្ឌិតសភាចារ្យ ហង់ ជួន ណារ៉ុន**

# មាតិកា


១. សេចក្តីផ្តើម ............................................................ ០១
២. ចក្ខុវិស័យ ............................................................ ០៤
៣. គោលបំណង ............................................................ ០៤
៤. គោលដៅ ............................................................ ០៤
៥. យុទ្ធសាស្ត្រ ............................................................ ០៤
៥.១. អភិវឌ្ឍក្របខណ្ឌច្បាប់ និងយន្តការ ............................................ ០៥
៥.២. សហការអន្តរក្រសួងក្នុងការកំណត់អត្តសញ្ញាណ ...................................... ០៥
៥.៣. អភិវឌ្ឍប្រព័ន្ធប្រមូលទិន្នន័យ និងព័ត៌មាន ............................................ ០៥
៥.៤. ផ្តល់ការអប់រំមានគុណភាព ប្រកបដោយបរិយាបន្ន និងសមធម៌ ........... ០៦
៥.៥. ធានាឱកាសអប់រំប្រកបដោយគុណភាព សមភាព និងសមធម៌សម្រាប់
សិស្សស្រីស្ថិតក្នុងសេចក្តីត្រូវការពិសេស ........................................ ០៧
៥.៦. អភិវឌ្ឍគំនូសប្លង់តាមបរិបទក្នុងប្រទេសសម្រាប់ការសាងសង់អគារសិក្សា
និងអនាម័យស្អាត ............................................................ ០៨
៥.៧. កសាងសមត្ថភាពគ្រូ និងគណៈគ្រប់គ្រងសាលារៀន ........................ ០៨
៥.៨. លើកកម្ពស់ការយល់ដឹងពីគោលនយោបាយស្តីពីការអប់រំបរិយាបន្ន ....... ០៩
៥.៩. ពង្រឹងចំណេះដឹង តួនាទី ការទទួលខុសត្រូវ និងការចូលរួមរបស់អ្នកពាក់ព័ន្ធ.. ០៩
៦. ផែនការសកម្មភាព ............................................................ ១០
៦.១. ការបង្កើតយន្តការ ............................................................ ១០
៦.២. ការបង្កើតក្របខណ្ឌគតិយុត្ត ............................................................ ១០
៦.៣. ការគាំទ្រហិរញ្ញវត្ថុ ............................................................ ១១
៦.៤. ការបណ្តុះបណ្តាលធនធានមនុស្ស ............................................................ ១១
៦.៥. ដំណើរការអនុវត្តគម្រោង ............................................................ ១១
៧. ការត្រួតពិនិត្យ និងការវាយតម្លៃ ............................................................ ១២
៨. សេចក្តីសន្និដ្ឋាន ............................................................ ១២
សទ្ទានុក្រម ............................................................ ១៣

# ១. សេចក្តីផ្តើម

នៅក្នុងពិភពលោក មានជនមានពិការភាពប្រមាណជាង១ពាន់លាននាក់ ក្នុងនោះជនមានពិការភាពចំនួន២០០លាននាក់កំពុងប្រឈមនឹងជីវភាពរស់នៅដោយលំបាកយោងតាមផែនការយុទ្ធសាស្ត្រជាតិស្តីពីពិការភាព ឆ្នាំ២០១៤-២០១៨។ នៅប៉ុន្មានឆ្នាំខាងមុខ បញ្ហាពិការភាពនឹងក្លាយជាក្តីបារម្ភកាន់តែធំធេង ដោយសារអត្រាពិការភាពកាន់តែកើនឡើង ដែលបណ្តាលមកពីជំងឺរ៉ាំរ៉ៃផ្សេងៗ ដូចជា ទឹកនោមផ្អែម មហារីក ជំងឺសរសៃឈាមបេះដូង និងដាច់សរសៃឈាមក្នុងខួរក្បាលជាដើម។ កត្តានេះទាមទារឱ្យយើងទាំងអស់គ្នាត្រូវបង្កើនការយកចិត្តទុកដាក់ខ្ពស់ ក្នុងការស្វែងរកដំណោះស្រាយទាន់ពេលវេលា។

សេចក្តីថ្លែងការណ៍ជាសកលស្តីពីសិទ្ធិមនុស្ស បានបញ្ជាក់ថាមនុស្សទាំងអស់កើតមកមានសិទ្ធិ សេរីភាព សមភាព និងសេចក្តីថ្លៃថ្នូរ។ នៅថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០០៦ មហាសន្និបាតអង្គការសហប្រជាជាតិ បានអនុម័តអនុសញ្ញាស្តីពីសិទ្ធិជនពិការ ដើម្បីធានាថាជនមានពិការភាពក៏ដូចជាមនុស្សជាតិទាំងអស់ត្រូវទទួលបានសិទ្ធិដូចគ្នា រួមមានសិទ្ធិពលរដ្ឋ សិទ្ធិនយោបាយ សិទ្ធិសេដ្ឋកិច្ចសង្គម និងសិទ្ធិវប្បធម៌ ដោយគ្មានការបែងចែកនិងរើសអើង។

តំបន់អាស៊ី និងប៉ាស៊ីហ្វិកមានជនមានពិការភាពប្រមាណ៦៥០លាននាក់ ស្មើនឹង ១៥%នៃប្រជាជនសរុបដែលកំពុងត្រូវបានបំភ្លេចឬមើលរំលង។ឆ្លើយតបនឹងបញ្ហានេះ នៅថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០១៣ សេចក្តីប្រកាសថ្នាក់រដ្ឋមន្ត្រីស្តីពីទស្សនវិស័យជនមានពិការភាពប្រចាំតំបន់អាស៊ី និងប៉ាស៊ីហ្វិក (២០១៣-២០២២) បានចេញសេចក្តីប្រកាសទីក្រុងអ៊ីនឈាន់ និងក្របខណ្ឌសម្រាប់សកម្មភាពឆ្ពោះទៅរកការអប់រំមានគុណភាព បរិយាបន្ន សមធម៌ និងការសិក្សាពេញមួយជីវិតសម្រាប់ទាំងអស់គ្នា។ សេចក្តីប្រកាសនេះបានកំណត់ចក្ខុវិស័យអប់រំឆ្នាំ២០៣០ សម្រាប់ការអភិវឌ្ឍប្រកបដោយចីរភាព និងផ្តោតលើការអប់រំបែប បរិយាបន្ន សមធម៌ សំដៅផ្តល់ឱ្យមនុស្សគ្រប់រូបទទួលបានឱកាសស្មើគ្នាដោយមិនគិតពី ភេទ អាយុ ពណ៌សម្បុរ ជាតិសាសន៍ ជនជាតិដើមភាគតិច ភាសា សាសនា គំនិតនយោបាយ ដើមកំណើត ឬ ពិការភាព ជាពិសេសជន

ងាយរងគ្រោះ។ សេចក្តីប្រកាសនេះបានគូសបញ្ជាក់ថា «គ្មាននរណាម្នាក់ ត្រូវបានទុកចោលឡើយ»។

ប្រទេសកម្ពុជាបានឆ្លងកាត់សង្គ្រាម និងរបបប្រល័យពូជសាសន៍ ដែលបានបន្សល់ទុកនូវផលវិបាកជាច្រើនរួមទាំងជនមានពិការភាពផងដែរ។ ប្រជាជនកម្ពុជាក៏ប្រឈមនឹងការធ្លាក់ទៅក្នុងពិការភាពដោយសារគ្រាប់មីន និងកាកសំណល់ជាតិផ្ទុះដែលសេសសល់ពីសង្គ្រាម។ ក្រៅពីនេះពិការភាពផ្សេងទៀតបណ្តាលមកពីគ្រោះថ្នាក់ចរាចរណ៍ គ្រោះថ្នាក់ការងារ ពិការពីកំណើត ចាស់ជរា និងមូលហេតុផ្សេងៗទៀត។ តាមរបាយការណ៍ចន្លោះជំរឿនឆ្នាំ២០១៣របស់ក្រសួងផែនការ ចំនួនជនមានពិការភាពកម្ពុជាមាន៣០១,៦២៩នាក់ ស្មើនឹង២.០៦% នៃប្រជាជនសរុប ១៤,៦៧៦,៥៩១នាក់ ក្នុងឆ្នាំ២០១៣។ក្នុងនោះបុរសមានពិការភាពមានចំនួន១៥៧,០០៨នាក់ស្មើនឹង៥២.០៥%និងស្ត្រីមានពិការភាពចំនួន ១៤៤,៦២២នាក់ស្មើនឹង៤៧.៩៥%។ កុមារមានពិការភាពអាយុពី០ឆ្នាំដល់១៤ឆ្នាំមានចំនួន ៣២,០៥៦នាក់ ស្មើនឹង១០.៦៣% នៃជនមានពិការភាពសរុប។ ទិន្នន័យនេះអាចធ្វើជាមូលដ្ឋានក្នុងការកំណត់សកម្មភាពជាក់ស្តែង និងការវិនិយោគប្រកបដោយជោគជ័យសម្រាប់ជនមានពិការភាពគ្រប់រូប។

រាជរដ្ឋាភិបាលកម្ពុជាបានដាក់ចេញយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ ដែលចតុកោណទី៤ មុំទី៣ អាទិភាពទី៤ ចែងអំពីការបន្តគោលនយោបាយជាតិចំពោះជនមានពិការភាព តាមរយៈក្រុមប្រឹក្សាសកម្មភាពជនពិការ ការពង្រឹងការអនុវត្តច្បាប់ស្តីពីកិច្ចការពារ និងលើកកម្ពស់សិទ្ធិជនពិការ ការជំរុញកិច្ចការពារ និងលើកកម្ពស់សិទ្ធិ និង សុខុមាលភាពជនមានពិការភាពស្របតាមអនុសញ្ញារបស់អង្គការសហប្រជាជាតិស្តីពីសិទ្ធិជនពិការ។ ផែនការយុទ្ធសាស្ត្រជាតិស្តីពីពិការភាពឆ្នាំ២០១៤-២០១៨មានទិសដៅជាយុទ្ធសាស្ត្រសំខាន់ៗចំនួន០៩ ផ្តោតលើការកាត់បន្ថយភាពក្រីក្ររបស់ជនមានពិការភាពការផ្តល់សេវាសុខភាពប្រកបដោយគុណភាព និងសមភាពព្រមទាំងការស្តារលទ្ធភាពសកម្មភាពកាយសម្បទា និងសតិបញ្ញា ការផ្តល់សេវាយុត្តិធម៌ ការការពារការរើសអើង ការរំលោភបំពាន ការប្រមាថ ការកេងប្រវ័ញ្ចលើជនមានពិការភាព។ ផែនការនេះក៏ផ្តោតទៅលើការអប់រំ ការចូលរួមក្នុងការសម្តែងមតិ ការទទួលព័ត៌មាន

និងទំនាក់ទំនងចំពោះជនមានពិការភាព ការធានាសមភាពយេនឌ័រ និងការលើកកម្ពស់សមត្ថភាពស្ត្រី និងកុមារមានពិការភាព ការពង្រឹង និងពង្រីកកិច្ចសហប្រតិបត្តិការជាមួយថ្នាក់អន្តរជាតិ។

ពីឆ្នាំ២០០៨-២០១៨ ក្រសួងបានអនុវត្តគោលនយោបាយស្តីពីការអប់រំកុមារពិការ ដែលធានាចំពោះកុមារ និងយុវជនកម្ពុជាទាំងអស់ឱ្យមានឱកាសស្មើៗគ្នាក្នុងការទទួលបានការអប់រំកម្រិតមូលដ្ឋានក្នុង និងក្រៅប្រព័ន្ធ ដោយមិនប្រកាន់កម្រិតជីវភាព ភេទ ភូមិសាស្ត្រ កាយសម្បទា និងជនជាតិឡើយ។ ជាក់ស្តែង ក្នុងឆ្នាំសិក្សា២០១៧-២០១៨កុមារនិងយុវជនមានពិការភាពចំនួន៥៤,៨៣៨នាក់ស្រី២២,៦២១នាក់បានចូលរៀន។

មាត្រា៧៤ នៃរដ្ឋធម្មនុញ្ញរបស់ព្រះរាជាណាចក្រកម្ពុជា បានកំណត់ថា «រដ្ឋជួយឧបត្ថម្ភជនពិការ និងដល់គ្រួសារយុទ្ធជនដែលបានបូជាជីវិតដើម្បីប្រទេសជាតិ»។ ច្បាប់ស្តីពីការអប់រំត្រង់មាត្រា៣៨ បានចែងថា «រដ្ឋលើកទឹកចិត្ត និងជំរុញឱ្យមានការអប់រំពិសេសសម្រាប់ជនពិការ និងអ្នកសិក្សាពូកែ ដែលមានទេពកោសល្យ និង/ឬបញ្ញាខ្ពស់។ ការអប់រំពិសេសផ្តល់ចំពោះអ្នកសិក្សាពូកែឱ្យស្របតាមបញ្ញា និងទេពកោសល្យរបស់អ្នកសិក្សានោះ និងផ្តល់លទ្ធភាពឱ្យអ្នកសិក្សាមានពិការភាពអាចសិក្សាបានដោយសមរម្យ»។ ច្បាប់ស្តីពីកិច្ចការពារ និងលើកកម្ពស់សិទ្ធិជនពិការត្រង់មាត្រា២៧រហូតដល់មាត្រា៣២បានលើកកម្ពស់សិស្សនិស្សិតមានពិការភាពគ្រប់រូបឱ្យមានសិទ្ធិចូលសិក្សា និងទទួលបានការអប់រំ។

ឆ្លើយតបទៅនឹងរដ្ឋធម្មនុញ្ញ ច្បាប់ស្តីពីការអប់រំ ច្បាប់ស្តីពីកិច្ចការពារ និងលើកកម្ពស់សិទ្ធិជនពិការ និងគោលនយោបាយនានាសំដៅឆ្លើយតបបញ្ហាខាងលើ ក្រសួងអប់រំ យុវជន និងកីឡា បានរៀបចំគោលនយោបាយស្តីពីការអប់រំបរិយាបន្ន។ គោលនយោបាយនេះបានកំណត់អំពីចក្ខុវិស័យ គោលបំណង គោលដៅ យុទ្ធសាស្ត្រ និងផែនការសកម្មភាពសម្រាប់ការអប់រំបរិយាបន្ន ដើម្បីលើកស្ទួយសិទ្ធិជនស្ថិតក្នុងសេចក្តីត្រូវការពិសេសឱ្យទទួលបានការអប់រំពេញមួយជីវិតប្រកបដោយគុណភាព បរិយាបន្ន និងសមធម៌។

## ២. ចក្ខុវិស័យ

គោលនយោបាយស្តីពីការអប់រំបរិយាបន្ន មានចក្ខុវិស័យអភិវឌ្ឍជនស្ថិតក្នុងសេចក្តីត្រូវការពិសេសគ្រប់រូបឱ្យទទួលបានការអប់រំពេញមួយជីវិតប្រកបដោយគុណភាព បរិយាបន្ន និងសមធម៌។

## ៣. គោលបំណង

គោលនយោបាយស្តីពីការអប់រំបរិយាបន្ន មានគោលបំណងបណ្តុះការអប់រំដល់ជនស្ថិតក្នុងសេចក្តីត្រូវការពិសេសឱ្យមានវិជ្ជាសម្បទា បំណិនសម្បទា និងចរិយាសម្បទាពេញលេញ ដើម្បីចូលរួមអភិវឌ្ឍសង្គមជាតិ។

## ៤. គោលដៅ

គោលនយោបាយស្តីពីការអប់រំបរិយាបន្នមានគោលដៅដូចខាងក្រោម ៖

៤.១. ធានាការកំណត់អត្តសញ្ញាណបឋម ការវាយតម្លៃ និងធ្វើអន្តរាគមន៍ទាន់ពេល។

៤.២. ផ្តល់សេវាអប់រំមានគុណភាពប្រកបដោយបរិយាបន្ន សមធម៌ និងការសិក្សាពេញមួយជីវិត។

៤.៣. កសាងសមត្ថភាព និងលើកកម្ពស់ការអភិវឌ្ឍជំនាញដល់គ្រូបង្រៀន និងគណៈគ្រប់គ្រងសាលារៀន។

៤.៤. លើកកម្ពស់ការយល់ដឹង និងការចូលរួម។

## ៥. យុទ្ធសាស្ត្រ

ដើម្បីសម្រេចគោលបំណងនិងគោលដៅខាងលើ គោលនយោបាយនេះមានយុទ្ធសាស្ត្រសំខាន់ៗដូចខាងក្រោម ៖

## ៩.១. អភិវឌ្ឍក្របខណ្ឌច្បាប់ និងយន្តការ

- រៀបចំលិខិតបទដ្ឋានគតិយុត្ត និងយន្តការសម្រាប់អនុវត្តគោលនយោបាយស្តីពីការអប់រំបរិយាបន្នឱ្យមានប្រសិទ្ធភាព
- លើកកម្ពស់ និងពន្លឿនការអនុវត្តគោលនយោបាយ ក្របខណ្ឌច្បាប់ យន្តការពាក់ព័ន្ធដែលមានស្រាប់ និងយន្តការថ្មី
- កសាងផែនការសកម្មភាពនានា ដោយមានសកម្មភាពជាក់លាក់ ពេលវេលា ធនធាន និងការទទួលខុសត្រូវ
- ផ្សព្វផ្សាយគោលនយោបាយ និងផែនការសកម្មភាពសម្រាប់ការអនុវត្តគោលនយោបាយ។

## ៩.២. សហការអន្តរក្រសួងក្នុងការកំណត់អត្តសញ្ញាណ

- សហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ ក្នុងការកំណត់អត្តសញ្ញាណបឋមដោយប្រើប្រាស់ឧបករណ៍កំណត់អត្តសញ្ញាណ
- សហការជាមួយស្ថាប័ន ភាគីពាក់ព័ន្ធ ដើម្បីវាយតម្លៃ និងធ្វើអន្តរាគមន៍ទាន់ពេលដល់ជនស្ថិតក្នុងសេចក្តីត្រូវការពិសេស
- កំណត់អត្តសញ្ញាណ វិភាគទិន្នន័យពិការភាព ផ្តល់ឧបករណ៍ជំនួយ និងផ្តល់សេវាស្តារលទ្ធភាពដើម្បីធានាបានការចូលរៀន។

## ៩.៣. អភិវឌ្ឍប្រព័ន្ធប្រមូលទិន្នន័យ និងព័ត៌មាន

- ធ្វើបច្ចុប្បន្នភាពប្រព័ន្ធព័ត៌មានគ្រប់គ្រងអប់រំ ដើម្បីបញ្ចូលព័ត៌មានអំពីតម្រូវការអប់រំពិសេសទៅក្នុងប្រព័ន្ធព័ត៌មានគ្រប់គ្រងអប់រំ
- សហការជាមួយក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ដើម្បីបញ្ចូលទិន្នន័យជនស្ថិតក្នុងសេចក្តីត្រូវការពិសេស ដែលកំពុងទទួលការបណ្តុះបណ្តាលវិជ្ជាជីវៈ
- សហការជាមួយក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ដើម្បីបញ្ចូលទិន្នន័យជនស្ថិតក្នុងសេចក្តីត្រូវការពិសេសទាំងក្នុង និងក្រៅសាលា

- វិភាគទិន្នន័យឱ្យបានទៀងទាត់ ដើម្បីកំណត់ពីបញ្ហាប្រឈមក្នុងការសិក្សា និងកង្វះខាតធនធានដែលត្រូវការសម្រាប់ជនស្ថិតក្នុងសេចក្តីត្រូវការពិសេស
- ធ្វើបច្ចុប្បន្នភាពជាប្រចាំនូវប្រព័ន្ធគ្រប់គ្រងទិន្នន័យនៃអ្នកផ្តល់សេវាលើការកំណត់អត្តសញ្ញាណបឋម ការវាយតម្លៃ និងការស្តារនីតិសម្បទា។

## ៩.៤. ផ្តល់ការអប់រំមានគុណភាពប្រកបដោយបរិយាបន្ន និងសមធម៌

- ធានាផ្តល់សេវាចុះឈ្មោះចូលរៀន និងផ្តល់លទ្ធភាពឱ្យអ្នកសិក្សាមានពិការភាពអាចសិក្សាបានសមរម្យ
- ធានាថាកម្មវិធីសិក្សា និងសៀវភៅសិក្សាគោលឆ្លើយតបទៅនឹងតម្រូវការផ្សេងគ្នារបស់អ្នកសិក្សាស្ថិតក្នុងសេចក្តីត្រូវការពិសេស
- ធានាឱ្យមានកម្មវិធីសិក្សាអប់រំពិសេសស្របតាមកម្មវិធីសិក្សា និងសៀវភៅសិក្សាគោល សម្រាប់ប្រើប្រាស់នៅគ្រប់គ្រឹះស្ថានសិក្សាសាធារណៈ និងឯកជន
- អភិវឌ្ឍកម្មវិធីសិក្សាអប់រំបរិយាបន្ន សម្រាប់សិស្សមានពិការភាពសតិបញ្ញា
- ណែនាំវិធីសាស្ត្របង្រៀន ដែលមានភាពបត់បែនទៅក្នុងកម្មវិធីសិក្សាជាតិដែលមានលក្ខណៈជាសិស្សមជ្ឈមណ្ឌល មានការចូលរួម និងសមស្របទៅនឹងវប្បធម៌
- ផ្តល់សម្ភារៈបង្រៀន និងរៀនឱ្យបានគ្រប់គ្រាន់ ដើម្បីបំពេញតម្រូវការរបស់អ្នកមានតម្រូវការអប់រំពិសេស
- រៀបចំផែនការអប់រំជាបុគ្គល សម្រាប់ជនស្ថិតក្នុងសេចក្តីត្រូវការពិសេសគ្រប់រូប ដោយកំណត់អំពីតម្រូវការសិក្សា
- ជំរុញការគាំទ្រវាល់សកម្មភាពសិក្សាស្រាវជ្រាវរបស់ជនស្ថិតក្នុងសេចក្តីត្រូវការពិសេស
- រៀបចំប្រព័ន្ធវាយតម្លៃមួយ ដែលមានភាពយុត្តិធម៌ និងភាពបត់បែន ដើម្បីឱ្យជនស្ថិតក្នុងសេចក្តី ត្រូវការពិសេសអាចចូលរួមប្រឡងបាន និងផ្តល់ទីកន្លែងប្រឡងសមរម្យ

- បង្កើតថ្នាក់សមាហរណកម្មនៅគ្រប់កម្រិតសិក្សា ដើម្បីផ្ដល់ការអប់រំឱ្យសមស្របនឹងអាយុរបស់ជនស្ថិតក្នុងសេចក្ដីត្រូវការពិសេស
- បង្កើតកម្មវិធីគាំពារសង្គម ដើម្បីផ្ដល់ការឧបត្ថម្ភគាំទ្រដល់ជនស្ថិតក្នុងសេចក្ដីត្រូវការពិសេស
- ធ្វើសមាហរណកម្មសិស្ស និស្សិតស្ថិតក្នុងសេចក្ដីត្រូវការពិសេសទៅក្នុងថ្នាក់រៀនចម្រុះតាមលទ្ធភាពដែលអាចធ្វើទៅបាន
- រៀបចំសេវាកីឡា សិល្បៈគ្រប់ប្រភេទ និងសេវាផ្សេងទៀតស្របតាមតម្រូវការ។

## ៤.៨. ធានាឱកាសអប់រំប្រកបដោយគុណភាព សមធម៌ និងសមធម៌សម្រាប់សិស្សស្រីស្ថិតក្នុងសេចក្ដីត្រូវការពិសេស

- អប់រំឪពុកម្ដាយ និងសហគមន៍ឱ្យយល់ពីសារប្រយោជន៍នៃការអប់រំកុមារី និងស្ត្រី
- រៀបចំកម្មវិធីលើកកម្ពស់សិទ្ធិទទួលបានសេវាអប់រំសម្រាប់កុមារី និងស្ត្រី
- ផ្ដល់ឱ្យសិស្សស្រីដែលមានតម្រូវការអប់រំពិសេស នូវការអប់រំស្ដីពីសុខភាព សុវត្ថិភាព និងការការពារ
- បង្កើនវិធានការដើម្បីការពារកុមារី និងស្ត្រី អំពីអំពើហិង្សា អំពើជួញដូរ និងការរំលោភបំពានគ្រប់រូបភាព
- ជំរុញកុមារី និងស្ត្រី ឱ្យចូលរួមធ្វើការសម្រេចចិត្តក្នុងសង្គម
- ធានាឱ្យកុមារី និងស្ត្រីបានចុះឈ្មោះចូលរៀន និងបញ្ចូលសមាសភាពក្នុងសកម្មភាពសាលារៀន និងសង្គម
- ធានាគាំទ្រលើការបណ្ដុះបណ្ដាលវិជ្ជាជីវៈ បំណិនជីវិត និងកីឡា ដល់កុមារី និងស្ត្រី
- ផ្ដល់អាហារូបករណ៍ដល់កុមារី និងស្ត្រី ដើម្បីបានចូលរៀនទាំងក្នុង និងក្រៅប្រទេស។

## ៨.៦. អតិវឌ្ឍគំនូសប្លង់តាមបរិបទក្នុងប្រទេស សម្រាប់ការសាងសង់អគារសិក្សា និងអនាម័យស្អាត

- ធានាថាគំនូសប្លង់ថ្នាក់ជាតិត្រូវបានបញ្ចូលក្នុងគោលការណ៍ណែនាំត្រួតពិនិត្យគុណភាពសំណង់
- ជំរុញឱ្យគ្រប់គ្រឹះស្ថានសិក្សាមានបន្ទប់ទឹកសមស្របនឹងតម្រូវការរបស់ជនស្ថិតក្នុងសេចក្តីត្រូវការពិសេស
- ធានាថាហេដ្ឋារចនាសម្ពន្ធរូបវន្តមានស្រាប់ត្រូវបានកែសម្រួល ឱ្យស្របតាមគំរូស្តង់ដាគំនូសប្លង់
- ជំរុញការសាងសង់ និងគ្រប់គ្រងអន្តេវាសិកដ្ឋាន សម្រាប់អ្នកសិក្សាស្ថិតក្នុងសេចក្តីត្រូវការពិសេស
- ធានាឱ្យមានបណ្ណាល័យ បន្ទប់ពិសោធន៍ និងសម្ភារៈមានស្តង់ដាសមស្របតាមតម្រូវការរបស់អ្នកសិក្សាស្ថិតក្នុងសេចក្តីត្រូវការពិសេស
- ធានាទីលានកីឡា បរិស្ថាន និងផ្លូវនៅក្នុងសាលារៀនឱ្យមានលក្ខណៈសមស្រប។

## ៨.៧. កសាងសមត្ថភាពគ្រូ និងគណៈគ្រប់គ្រងសាលារៀន

- ផ្តល់អាទិភាពដល់អ្នកសិក្សាមានពិការភាពក្នុងការប្រឡងចូលក្នុងក្របខណ្ឌគ្រូបង្រៀន
- បណ្តុះបណ្តាលគ្រូសម្រាប់បង្រៀនជនស្ថិតក្នុងសេចក្តីត្រូវការពិសេសនៅគ្រប់ភូមិសិក្សា
- ផ្តល់អត្ថប្រយោជន៍បន្ថែមដល់គ្រូ ដែលមានគុណវុឌ្ឍិគ្រប់គ្រាន់ក្នុងការបង្រៀនសិស្សមានពិការភាព
- ពង្រឹងសមត្ថភាពគ្រូបង្រៀនលើជំនាញអប់រំបរិយាបន្ន ស្របតាមការរីកចម្រើននៃបច្ចេកវិទ្យា និងបរិបទសកលភាវូបនីយកម្ម
- ពង្រឹងកម្មវិធីគរុកោសល្យអំពីពិការភាពសម្រាប់បំប៉នគ្រូ
- រៀបចំឱ្យមានពហុជំនាញផ្នែកអប់រំបរិយាបន្នសម្រាប់គ្រូបង្រៀនអ្នកសិក្សា

ស្ថិតក្នុងសេចក្តីត្រូវការពិសេស

- រៀបចំកម្មវិធីបណ្តុះបណ្តាល និងវិក្រឹតការគ្រូ។

## ៥.៨. លើកកម្ពស់ការយល់ដឹងពីគោលនយោបាយស្តីពីការអប់រំបរិយាបន្ន

- អភិវឌ្ឍយុទ្ធសាស្ត្រប្រព័ន្ធផ្សព្វផ្សាយនៅកម្រិតថ្នាក់ក្រុង ស្រុក ខណ្ឌ ថ្នាក់រាជធានី ខេត្ត និងថ្នាក់ជាតិ ដោយប្រើប្រាស់វិធីសាស្ត្រផ្សេងៗ
- រៀបចំសេចក្តីណែនាំស្តីពីការអនុវត្តល្អៗ សម្រាប់គ្រឹះស្ថានសិក្សាទាំងអស់ប្រើប្រាស់ក្នុងពេលផ្សព្វផ្សាយ
- សហការជាមួយគ្រឹះស្ថានសិក្សាឯកជន ដើម្បីលើកកម្ពស់ជនស្ថិតក្នុងសេចក្តីត្រូវការពិសេសឱ្យចូលរៀន
- ធានាផ្តល់សិទ្ធិ និងការគាំទ្រពិសេសក្នុងដំណើរការសិក្សារបស់អ្នកសិក្សាស្ថិតក្នុងសេចក្តីត្រូវការពិសេស។

## ៥.៩. ពង្រឹងចំណេះដឹង តួនាទី ការទទួលខុសត្រូវ និងការចូលរួមរបស់អ្នកពាក់ព័ន្ធ

- លើកកម្ពស់ការយល់ដឹងពីសិទ្ធិទទួលបានការអប់រំសម្រាប់ជនមានតម្រូវការអប់រំពិសេស
- បោះពុម្ពគោលនយោបាយនេះជាអក្សរស្ទាប
- ពង្រឹងចំណេះដឹង តួនាទី និងការទទួលខុសត្រូវរបស់អ្នកពាក់ព័ន្ធទាំងអស់ក្នុងការអនុវត្តគោលនយោបាយនេះ
- ជំរុញ និងលើកទឹកចិត្តមាតាបិតា សហគមន៍ឱ្យយល់ដឹងពីពិការភាព និងចែករំលែកព័ត៌មាន បទពិសោធដើម្បីគាំទ្រជនពិការ និងគ្រួសារក្រីក្រដែលមានកូនមានពិការភាពឱ្យមកទទួលការអប់រំ
- បង្កើតមូលនិធិសមធម៌សង្គម ឱ្យសាលារៀនទទួលបានមូលនិធិបន្ថែម ដើម្បីជួយដល់ជនស្ថិតក្នុងសេចក្តីត្រូវការពិសេស។

# ៦. ផែនការសកម្មភាព

ដើម្បីសម្រេចយុទ្ធសាស្ត្រខាងលើ ត្រូវយកចិត្តទុកដាក់លើសកម្មភាពមួយចំនួនដូចខាងក្រោម ៖

## ៦.១. ការបង្កើតយន្តការ

- កែសម្រួលក្រុមការងារសកម្មភាពកុមារមានពិការភាព ថ្នាក់ក្រសួងអប់រំ យុវជន និងកីឡា
- កែសម្រួលក្រុមការងារសកម្មភាពកុមារមានពិការភាពថ្នាក់មន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត ការិយាល័យអប់រំ យុវជន និងកីឡាក្រុង ស្រុក ខណ្ឌ និងសាលារៀន
- បង្កើតមូលនិធិសមធម៌សង្គម សម្រាប់ជួយជនស្ថិតក្នុងសេចក្ដីត្រូវការពិសេស។ មូលនិធិសមធម៌សង្គមនេះត្រូវរៀបចំគណៈកម្មការគ្រប់គ្រងដើម្បីប្រមូលថវិកានៅគ្រប់ទីកន្លែង ជាពិសេសនៅតាមទីវត្តអារាម ភោជនីយដ្ឋាននានា ។

## ៦.២. ការបង្កើតក្របខណ្ឌគតិយុត្ត

- ក្រុមការងារសកម្មភាពកុមារមានពិការភាពថ្នាក់ក្រសួង ត្រូវដឹកនាំដោយរដ្ឋមន្ត្រី ក្រសួងអប់រំ យុវជន និងកីឡា។ សមាសភាពជាក់ស្ដែងរបស់ក្រុមការងារនេះត្រូវកំណត់ដោយប្រកាសរបស់ក្រសួងអប់រំ យុវជន និងកីឡា
- ក្រុមការងារសកម្មភាពកុមារមានពិការភាពថ្នាក់មន្ទីរ ដឹកនាំដោយប្រធានមន្ទីរអប់រំ យុវជន និង កីឡា រាជធានី ខេត្ត។ ក្រុមការងារសកម្មភាពកុមារមានពិការភាពថ្នាក់ក្រុង ស្រុក ខណ្ឌ ដឹកនាំដោយប្រធានការិយាល័យអប់រំ យុវជន និងកីឡាក្រុង ស្រុក ខណ្ឌ។ ក្រុមការងារសកម្មភាពកុមារមានពិការភាពថ្នាក់សាលារៀន ដឹកនាំដោយនាយក ឬនាយិកាសាលារៀន។ សមាសភាពជាក់ស្ដែងរបស់ក្រុមការងារសកម្មភាពកុមារមានពិការភាពត្រូវកំណត់ដោយលិខិតបង្គាប់ការរបស់មន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត

ការិយាល័យ អប់រំ យុវជន និងកីឡាក្រុង ស្រុក ខណ្ឌ និងសាលារៀន

- គណៈកម្មការគ្រប់គ្រងមូលនិធិសមធម៌សង្គម កំណត់ដោយប្រកាសរបស់ក្រសួងអប់រំ យុវជន និងកីឡា។

## ៦.៣. ការគាំទ្រហិរញ្ញវត្ថុ

ដើម្បីគាំទ្រយន្តការ និងដំណើរការសកម្មភាពតាមយុទ្ធសាស្ត្រនីមួយៗ ត្រូវមានថវិកាដែលបានមកពីប្រភព៖

- ថវិការបស់ក្រសួងអប់រំ យុវជន និងកីឡា
- ថវិកាដៃគូអភិវឌ្ឍ និងសប្បុរសជន
- ថវិកាដែលជាមូលនិធិសមធម៌សង្គម
- ថវិកាមកពីប្រភពផ្សេងទៀត។

## ៦.៤. ការបណ្តុះបណ្តាលធនធានមនុស្ស

ដើម្បីធានាប្រសិទ្ធភាពនៃការអនុវត្តន៍គោលនយោបាយស្តីពីការអប់រំបរិយាបន្នក្រសួងត្រូវយកចិត្តទុកដាក់បណ្តុះបណ្តាលសមត្ថភាពក្រុមការងារសកម្មភាពកុមារមានពិការភាពនៅថ្នាក់ជាតិ ថ្នាក់រាជធានី ខេត្ត ថ្នាក់ក្រុង ស្រុក ខណ្ឌ និងថ្នាក់សាលារៀន និងត្រូវពង្រឹងសមត្ថភាពគ្រូនៅវិទ្យាស្ថានជាតិអប់រំពិសេសដើម្បីបើកវគ្គបំប៉នពង្រឹងសមត្ថភាពគ្រូនៅតាមគ្រឹះស្ថានសិក្សា។

## ៦.៥. ដំណើរការអនុវត្តគម្រោង

រៀបចំផែនការអនុវត្តគោលនយោបាយស្តីពីការអប់រំបរិយាបន្នរយៈពេលមធ្យម រយៈពេលវែងដោយពិគ្រោះយោបល់ជាមួយអ្នកពាក់ព័ន្ធ ដើម្បីទទួលបានការគាំទ្រ និងធានាប្រសិទ្ធភាពនៃការអនុវត្ត។ ផែនការនេះត្រូវឆ្លុះបញ្ចាំងចក្ខុវិស័យរបស់គោលនយោបាយ និងត្រូវបំពេញគ្នាទៅវិញទៅមកជាមួយនឹងគោលនយោបាយផ្សេងៗទៀត។ផែនការសកម្មភាព សម្រា ប់ការអប់រំបរិយាបន្នត្រូវគ្របដណ្តប់ពីមត្តេយ្យសិក្សារហូតដល់ឧត្តមសិក្សា។

## ៧. ការត្រួតពិនិត្យ និងការវាយតម្លៃ

ការអនុវត្តគោលនយោបាយស្តីពីការអប់រំបរិយាបន្នមានគុណភាព និងប្រសិទ្ធភាព ចាំបាច់ត្រូវមានប្រព័ន្ធត្រួតពិនិត្យ និងវាយតម្លៃឡើងវិញ ព្រមទាំងលើកសំណើកែលម្អការអនុវត្តន៍គោលនយោបាយដោយផ្តោតលើ ៖

- ចំណុចដៅ និងយុទ្ធសាស្រ្តទាំងប្រាំបួននៃគោលនយោបាយ
- សូចនាករនៃផែនការសកម្មភាពសម្រាប់ការអប់រំបរិយាបន្ន
- លទ្ធផលដែលទទួលបានធៀបនឹងចំណុចដៅ សូចនាករ
- ផលប្រយោជន៍ដែលទទួលបានក្រោយការសិក្សា។

## ៨. សេចក្តីសន្និដ្ឋាន

គោលនយោបាយស្តីពីការអប់រំបរិយាបន្នបានកំណត់នូវចក្ខុវិស័យ គោលបំណង គោលដៅ និងយុទ្ធសាស្រ្ត លើការអប់រំសម្រាប់ជនស្ថិតក្នុងសេចក្តីត្រូវការពិសេស ដែលជាផែនទីបង្ហាញផ្លូវសម្រាប់ឱ្យជនស្ថិតក្នុងសេចក្តីត្រូវការពិសេស ទទួលបានការអប់រំ មានវិជ្ជាសម្បទា បំណិនសម្បទា និងចរិយាសម្បទាពេញលេញ ដើម្បីក្លាយជាពលរដ្ឋដែលមានជំនាញ អាចចូលរួមដោះស្រាយបញ្ហាជីវភាពរស់នៅប្រចាំថ្ងៃ និងរួមចំណែកអភិវឌ្ឍសង្គមជាតិ។

ការអនុវត្តគោលនយោបាយនេះទទួលបានជោគជ័យ ទាមទារឱ្យមានធនធានមនុស្ស ធនធានហិរញ្ញវត្ថុ និងធនធានសម្ភារបរិក្ខារ ដែលជាកត្តាមិនអាចខ្វះបាន។ ក្រសួងអប់រំ យុវជន និងកីឡា សង្ឃឹម និងជឿជាក់ថា អង្គភាពពាក់ព័ន្ធ ដៃគូអភិវឌ្ឍ មាតាបិតា សហគមន៍ គ្រឹះស្ថានសិក្សាសាធារណៈ និងឯកជន និងអ្នកពាក់ព័ន្ធទាំងអស់នឹងចូលរួមចំណែកក្នុងការជំរុញ ផ្សព្វផ្សាយ គាំទ្រ និងអនុវត្តគោលនយោបាយនេះប្រកបដោយប្រសិទ្ធភាព និងជោគជ័យ។

## សទ្ទានុក្រម

**ការសម្របសម្រួលសមរម្យ៖** គឺសំដៅដល់ការកែសម្រួល និងការសម្របសម្រួលទីកន្លែង សម្ភារ ឬឧបករណ៍ជំនួយផ្សេងៗដើម្បីជានាថាជនស្ថិតក្នុងសេចក្តីត្រូវការពិសេសអាចចូលរួមពេញលេញនៅក្នុងដំណើរការបង្រៀន និងរៀន។

**ការអប់រំបរិយាបន្ន៖** គឺសំដៅដល់ដំណើរការដោះស្រាយ និងឆ្លើយតបទៅនឹងសេចក្តីត្រូវការផ្សេងៗគ្នារបស់បុគ្គល និងក្រុមនានាតាមរយៈការលើកកម្ពស់ការចូលរួមក្នុងការសិក្សា វប្បធម៌ និងសហគមន៍ និងការកាត់បន្ថយ និងលុបបំបាត់ការបំភ្លេចចោលឬផាត់ចេញពីប្រព័ន្ធអប់រំ។ ការអប់រំនេះទាមទារឱ្យមានការផ្លាស់ប្តូរ និងកែសម្រួលខ្លឹមសារមេរៀន យុទ្ធវិធី ទម្រង់ និងយុទ្ធសាស្ត្រ ដើម្បីបញ្ចូលជនគ្រប់រូបទៅក្នុងប្រព័ន្ធអប់រំ។ ការអប់រំបរិយាបន្ន គឺជាដំណើរការពង្រីកសមត្ថភាពរបស់ប្រព័ន្ធអប់រំក្នុងការផ្តល់សេវាកម្មដល់អ្នកសិក្សាគ្រប់រូប។

**ជនស្ថិតក្នុងសេចក្តីត្រូវការពិសេស៖** គឺសំដៅដល់ជនទាំងឡាយណាដែលមានពិការភាព ហើយត្រូវការគាំទ្របន្ថែម និងវិធីសាស្ត្របង្រៀនពិសេសដើម្បីសម្រួលដល់ការសិក្សារបស់ពួកគេ។

**ជនមានទេពកោសល្យ និង/ ឬបញ្ញាខ្ពស់៖** គឺសំដៅដល់ជនទាំងឡាយណាដែលមានសមត្ថភាពមួយ ឬច្រើនខ្ពស់ជាងអ្នកដែលមានអាយុប្រហាក់ប្រហែលគ្នា។ ជនដែលមានបញ្ញាខ្ពស់ មានសមត្ថភាពពូកែលើមុខវិជ្ជានៅក្នុងថ្នាក់រៀន។ រីឯជនដែលមានទេពកោសល្យ មានសមត្ថភាពពូកែលើជំនាញផ្សេងៗ ដូចជាសិល្បៈ ការរចនាដូរ្យតន្ត្រី របាំ និងការសំដែងសិល្បៈ។ ជនប្រភេទនេះ អាចជាជនស្ថិតក្នុងសេចក្តីត្រូវការពិសេស ប្រសិនបើពួកគាត់មានសេចក្តីត្រូវការពិសេសណាមួយដែលរាំងស្ទះដល់ការសិក្សា។

**សេចក្តីត្រូវការអប់រំពិសេស៖** គឺសំដៅដល់ប្រព័ន្ធអប់រំមួយដែលរៀបចំឡើងដើម្បីជួយសម្រួលដល់ការសិក្សារបស់ជនដែលត្រូវការការគាំទ្របន្ថែម និងវិធីសាស្ត្របង្រៀន ដែលមានភាពបត់បែន ដោយសារហេតុផលផ្សេងៗ ដើម្បីចូលរួម និងសម្រេច

បាននូវវត្ថុបំណងក្នុងកម្មវិធីអប់រំ។ ហេតុផលទាំងនេះមានដូចជាគុណវិបត្តិផ្នែកកាយសម្បទា ឥរិយាបថ សតិបញ្ញា ភាសា វប្បធម៌ ការធ្វើចំណាកស្រុក ការរស់នៅតាមចិញ្ចើមផ្លូវ ភាពក្រីក្រ សមត្ថភាពផ្នែកសង្គម និងសតិអារម្មណ៍។ កម្មវិធីអប់រំសម្រាប់តម្រូវការអប់រំពិសេសនឹងអនុវត្តតាមកម្មវិធីសិក្សានៅក្នុងប្រព័ន្ធអប់រំធម្មតា និងប្រព័ន្ធអប់រំមួយផ្សេងទៀត ប៉ុន្តែកម្មវិធីអប់រំនេះ បានគិតគូរអំពីតម្រូវការផ្សេងគ្នារបស់បុគ្គលនីមួយៗ តាមរយៈការផ្តល់ធនធានជាក់លាក់ និងខ្លឹមសារមេរៀន ឬវត្ថុបំណងសិក្សាដែលត្រូវបានកែសម្រួល។

**ថ្នាក់អប់រំបរិយាបន្ន៖** គឺសំដៅដល់ការដាក់បញ្ចូលកុមារទាំងអស់ឱ្យរៀនជាមួយគ្នានៅក្នុងប្រព័ន្ធអប់រំទាំងក្នុង ឬក្រៅប្រព័ន្ធអប់រំដោយមិនបែងចែកអំពីភេទ អត្តចរិតកាយសម្បទា បញ្ញាស្មារតី ស្ថានភាពសង្គម ភាសា វប្បធម៌ សាសនា ឬលក្ខណៈផ្សេងៗទៀត។

**ថ្នាក់សមាហរណកម្ម៖** គឺសំដៅដល់ថ្នាក់រៀនដោយឡែកសម្រាប់តែសិស្សមានពិការភាពនៅក្នុងសាលារៀនធម្មតា។ ជាធម្មតាសិស្សដែលមានពិការភាពដូចជាបញ្ហាស្តាប់ ឬខ្សោយបញ្ញា នឹងត្រូវដាក់ឱ្យរៀនជាមួយគ្នា ដើម្បីមានភាពងាយស្រួលក្នុងការណែនាំ និងរៀនសូត្រ។ នៅក្នុងថ្នាក់សមាហរណកម្ម ពួកគេនឹងទទួលបាននូវសេវាពិសេស ដូចជាការណែនាំអំពីអក្សរស្ទាប ឬភាសាសញ្ញាតាមរយៈគ្រូដែលបានបណ្តុះបណ្តាលពិសេស ថែមទាំងមានឱកាសទាក់ទងជាមួយកុមារមិនមានពិការភាព។ នៅពេលដែលពួកគេទទួលបានជំនាញចាំបាច់តាមរយៈសេវាទាំងនេះ ដូចជាការអាន និងសរសេរអក្សរស្ទាប ពួកគេអាចផ្លាស់ទៅរៀននៅថ្នាក់រៀនធម្មតា ប្រសិនបើគ្រូបានទទួលការបណ្តុះបណ្តាលពិសេស ឬពួកគេអាចបន្តទទួលសេវាពិសេសនៅទីនោះ។

**ផែនការអប់រំជាបុគ្គល៖** គឺសំដៅដល់វិធីសាស្ត្រឆ្លើយតបទៅនឹងតម្រូវការរៀនរបស់កុមារទូទៅ ការអភិវឌ្ឍន៍ការសិក្សារបស់កុមារស្ថិតក្នុងសេចក្តីត្រូវការពិសេស តម្រូវ

ឱ្យគ្រូប្រចាំថ្នាក់មានផែនការតាមដាន និងវាយតម្លៃការរីកចម្រើនរបស់គេជាប្រចាំ។ ផែនការអប់រំជាបុគ្គល គឺជាផែនការសកម្មភាពបន្ថែមលើកិច្ចតែងការបង្រៀនរបស់គ្រូក្នុងការកំណត់ពីតម្រូវការរបស់កុមារក្នុងការសិក្សា និង ដើម្បីរកវិធីផ្សេងៗជួយកុមារឱ្យបានសមស្របតាមតម្រូវការ។ នៅដំណាច់ឆ្នាំ គ្រូត្រូវពិនិត្យមើលផែនការសកម្មភាពសាជាថ្មី ដើម្បីវាយតម្លៃ ថាតើវិធីដែលបានប្រើមានប្រសិទ្ធភាពដែរឬទេ ហើយបានសម្រេចតាមគោលបំណងដែរឬទេ និងអ្វីខ្លះដែលត្រូវកែលម្អ។

**ពិការភាព៖** គឺសំដៅដល់ការបាត់បង់ ខូចខាត ខ្វះខាត ឬអន់ខ្សោយរយៈពេលយូរផ្នែករាងកាយ សតិបញ្ញា ឬផ្នែកអាកប្បកិរិយា ដែលបណ្ដាលឱ្យបាត់បង់ការបំពេញមុខងារ និងការចូលរួមក្នុងសកម្មភាពរស់នៅប្រចាំថ្ងៃ។

**សមធម៌៖** គឺសំដៅដល់ការទទួលបានសេវាកម្ម ដែលឆ្លើយតបទៅនឹងតម្រូវការផ្សេងៗរបស់បុគ្គល ឬក្រុមនានា។ សម្រាប់វិស័យអប់រំ សមធម៌កើតមានឡើងនៅពេលដែលអ្នកសិក្សាស្ថិតក្នុងសេចក្ដីត្រូវការពិសេសទទួលបានជំនួយ និងការសម្របសម្រួលសមស្រប ដើម្បីឱ្យពួកគាត់អាចចុះឈ្មោះ និងរៀនទាន់សិស្សដទៃទៀត។

**សាលាអប់រំពិសេស៖** គឺសំដៅដល់សាលាសម្រាប់តែសិស្សមានតម្រូវការអប់រំពិសេស។ ឧទាហរណ៍៖ សាលាមានតែសិស្សអូធីសឹម ឬសាលាមានតែសិស្សពិការភ្នែក ឬខ្សោយគំហើញ។

**ឧបករណ៍ជំនួយ៖** គឺសំដៅដល់គ្រឿងប្រដាប់ពិសេសសម្រាប់សម្រួលការលំបាករបស់កុមារមានពិការភាព។ ឧទាហរណ៍៖ រទេះរុញ ឬឈើច្រត់ ជួយសម្រួលដល់ការធ្វើដំណើររបស់កុមារដែលមានបញ្ហាចលនា។ វ៉ែនតា ជួយសម្រួលដល់កុមារដែលមានបញ្ហាមើល។